ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញៈ ថ្ងៃទី ១៩ ខែធ្នូ ២០១៣ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# ប្រជុំពិភាក្សាការគ្រប់គ្រង និងការងារពាក់ព័ន្ធ
# ស្តីពីសវនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ

ឆ្នាំពីរពាន់ដប់បី ខែធ្នូ ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោងប្រាំបួនព្រឹក នៅសាលប្រជុំសាលាជាតិពន្ធដារ របស់អគ្គនាយកដ្ឋានពន្ធដារ បានបើកកិច្ចប្រជុំពិភាក្សាការគ្រប់គ្រង និងការងារដែលពាក់ព័ន្ធនឹងកិច្ចការសវនកម្ម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានវត្តមានចូលរួមពីសំណាក់ ឯកឧត្តមអគ្គនាយករងទទួលបន្ទុក និងវត្តមានរបស់លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខណ្ឌ ព្រមទាំងលោក-លោកស្រី មន្ត្រីសវនករនៃនាយកដ្ឋានសវនកម្មសហគ្រាស និងសាខាពន្ធដារខណ្ឌទាំង៧នៃរាជធានីភ្នំពេញ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងជាប្រធានអង្គប្រជុំ បានសម្តែងនូវកិច្ចស្វាគមន៍ ព្រមទាំងបានថ្លែងនូវអំណរគុណចំពោះឯកឧត្តមអគ្គនាយករង លោក-លោកស្រីជាថ្នាក់ដឹកនាំនាយកដ្ឋានពាក់ព័ន្ធ និងមន្ត្រីសវនករនៃអគ្គនាយកដ្ឋាន ដែលបានអញ្ជើញចូលរួមប្រជុំនាវេលាព្រឹកនេះ ។ ឯកឧត្តម ប្រធានអង្គប្រជុំ បានបញ្ជាក់ជូនអង្គប្រជុំថា កិច្ចប្រជុំនេះត្រូវបានរៀបចំធ្វើឡើងក្នុងគោលបំណងជួបជុំសំណេះសំណាល និងកោតសរសើរចំពោះស្នាដៃរបស់សវនករនៃអគ្គនាយកដ្ឋានពន្ធដារ ដែលបានខិតខំបំពេញការងារបានជោគជ័យ ដែលស្តែងចេញតាមរយៈលទ្ធផលនៃការកើនឡើងនូវចំណូលពន្ធសម្រាប់ឆ្នាំ២០១៣ របស់សាខាពន្ធដារខេត្ត-ខណ្ឌ និងរបស់នាយកដ្ឋានមួយចំនួននៅថ្នាក់កណ្តាល នៃអគ្គនាយកដ្ឋានពន្ធដារ លើសបណ្តាឆ្នាំមុនៗ ។




ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ




ឯកឧត្តម **គង់ វិបុល** និងថ្នាក់ដឹកនាំ មន្ត្រីសវនករពន្ធដារទាំងអស់ យល់ព្រមនិងប្តេជ្ញាក្នុងការធ្វើកំណែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ

ទន្ទឹមនេះ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ក៏បានដាស់តឿន ក្រើនរំលឹកដល់មន្ត្រីសវនករទាំងអស់ ឲ្យប្រកាន់ខ្ជាប់ជានិច្ចនូវក្រមសីលធម៌ វិជ្ជាជីវៈការងារ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ព្រោះហេតុថា រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភាជាតិ ក្រោមការដឹកនាំរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជាដែលបាន ដាក់ចេញនូវគោលនយោបាយកែទម្រង់ស៊ីជម្រៅ និងការពង្រឹងអភិបាលកិច្ចល្អ ក៏ដូចជាការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្នុងការកែប្រែមុខមាត់ថ្មី របៀបរបបការងារថ្មីនៅតាមស្ថាប័នរដ្ឋ ជាពិសេស អគ្គ

នាយកដ្ឋានពន្ធដារ ដែលជាស្ថាប័នគន្លឹះក្នុងការប្រមូលចំណូលជូនជាតិ ដែលត្រូវតែទាមទារនូវការកែទម្រង់ជាចាំបាច់ ។

អនុវត្តតាមគោលនយោបាយកែទម្រង់របស់រាជរដ្ឋាភិបាល ឯកឧត្តមប្រធានអង្គប្រជុំ បានផ្តល់អនុសាសន៍ណែនាំផ្តាំផ្ញើដល់មន្ត្រីសវនករទាំងអស់ នៃគ្រប់សាខាពន្ធដារខណ្ឌទាំងអស់ ត្រូវពង្រឹងប្រសិទ្ធភាពការងាររបស់ខ្លួន និងត្រូវអប់រំ ណែនាំមន្ត្រីក្រោមឱវាទ ឲ្យប្រកាន់យកក្រមសីលធម៌ខ្ពស់ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដោយបញ្ឈប់ជាបន្ទាន់នូវការប្រព្រឹត្តិអំពើពុករលួយ។ មន្ត្រីពន្ធដារគ្រប់រូប ត្រូវផ្លាស់ប្តូរផ្នត់គំនិតរបៀបរបបនៃការធ្វើការងារ និងមានទំនួលខុសត្រូវខ្ពស់ចំពោះភារកិច្ចរបស់ខ្លួន ។ ថ្នាក់ដឹកនាំរបស់អគ្គនាយកដ្ឋានពន្ធដារ ពិតជាមានបំណងប្រែក្លាយស្ថាប័នជាតិមួយនេះ ទៅជាស្ថាប័នដែលទទួលបាននូវទំនុកចិត្តខ្ពស់ពីគ្រប់មជ្ឈដ្ឋានសាធារណៈ តាមរយៈការបង្កើនសមត្ថភាពមន្ត្រីពន្ធដារ, ការបង្កើនការផ្តល់សេវាល្អជូនអ្នកជាប់ពន្ធ ជាដើម ។




អគ្គនាយកដ្ឋានពន្ធដារ